THE GLOBAL GOALS
For Sustainable Development

Movimiento Mundial por la Infancia de Latinoamérica y El Caribe

unicef



# ពិភពលោក យើងចង់បាន

## មគ្គុទេសក៍គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពសម្រាប់កុមារនិងយុវជន

បកប្រែ និងបោះពុម្ពឡើងវិញ ដោយអង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា
បោះពុម្ព៖ ខែកញ្ញា ឆ្នាំ២០១៦
www.unicef.org/cambodia

កែសម្រួលការបោះពុម្ពផ្សាយដោយ
The Latin America and Caribbean movement for Children – MMI-LAC
បោះពុម្ពផ្សាយលើកទី១៖ ខែតុលា ឆ្នាំ២០១៤
បោះពុម្ពផ្សាយលើកទី២៖ ខែសីហា ឆ្នាំ២០១៥

ក្រុមការងារក្រោយឆ្នាំ២០១៥៖
Álvaro Sepúlveda – Marist Foundation for International Solidarity - FMSI
Carmen Alvarez e Juan Carlos Morales –Viva Network
Jorge Freyre – Save the Children/REDLAMYC
Katia Dantas and Pilar Ramírez –International Centre for Missing & Exploited Children – ICMEC
Patricia Horna and Amanda Rives – World Vision International
Virginia Murillo – Defense for Children International - DNI

អ្នកសម្របសម្រួលគម្រោង៖
Inés Invernizzi –SOS Children's Villages International
Patricia Toquica – SOS Children's Villages International

អ្នកនិពន្ធ៖
Dora Bardales
Paola Arenas

ការសម្របសម្រួល និងរៀបចំឯកសារ
បោះពុម្ពផ្សាយទាំងមូល៖
SOS Children's Villages International
Save the Children
UNICEF
World's Largest Lesson

www.movimientoporlainfancia.org

# ពិភពលោក យើងចង់បាន

មគ្គុទេសក៍គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពសម្រាប់កុមារនិងយុវជន

# អារម្ភកថា

យើងខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមបង្ហាញជូននូវឯកសារដែលមានចំណងជើងថា "ពិភពលោក យើងចង់បាន" ដែលផលិតដោយ The Latin America and Caribbean movement for Children ដើម្បីបង្ហាញកុមារ និងយុវជនទូទាំងពិភពលោកស្គាល់ពីគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

គោលដៅទាំងនេះ បានទទួលការឯកភាព និងអនុម័តជាផ្លូវការដោយមេដឹកនាំពិភពលោក នៅក្នុងមហាសន្និបាទអង្គការសហប្រជាជាតិ កាលពីខែកញ្ញា ឆ្នាំ២០១៥។ ប៉ុន្តែ តើគោលដៅទាំងនេះពាក់ព័ន្ធជាមួយនឹងកុមារ យុវជន និងពលរដ្ឋគ្រប់រូបនៅក្នុងប្រទេសកម្ពុជាដែរឬទេ? ចម្លើយគឺវាពិតជាមានភាពពាក់ព័ន្ធប្រាកដមែន!

កុមារក្នុងប្រទេសកម្ពុជា ចម្រើនវ័យក្នុងរយៈពេលមួយ ដែលប្រទេសកំពុងឆ្លងកាត់វឌ្ឍនភាពគួរឲ្យកត់សម្គាល់។ ឧទាហរណ៍ ឥឡូវនេះ ភាពក្រីក្រមានការថយចុះ បើធៀបនឹងកាលពី១០ឆ្នាំមុន។ កុមារដែលមិនគួរស្លាប់ដោយសារមូលហេតុដែលអាចបង្ការបាន មានចំនួនតិចជាងមុន ដោយសារសេវាថែទាំសុខភាព និងសេវាផ្សេងទៀតមានលក្ខណៈល្អប្រសើរជាងមុន។ មានកុមារច្រើនជាងមុនបានរៀនចប់ថ្នាក់បឋមសិក្សា និងឆ្លងទៅភូមិសិក្សា និងមធ្យមសិក្សា។ ទាំងនេះគ្រាន់តែជាឧទាហរណ៍មួយចំនួនតូច ដែលបង្ហាញពីជោគជ័យដែលសម្រេចបានកន្លងមកសម្រាប់កុមារ និងមនុស្សគ្រប់គ្នា ក្នុងប្រទេសកម្ពុជា។

ប៉ុន្តែនៅមានការងារជាច្រើនទៀត ដែលយើងចាំបាច់ត្រូវធ្វើ ដើម្បីឲ្យកុមារគ្រប់រូបក្នុងប្រទេសកម្ពុជា អាចចម្រើនវ័យប្រកបដោយសុខភាពល្អ អាចទទួលបានការអប់រំប្រកបដោយគុណភាព ទទួលបានការការពារពីអំពើហិង្សានិងការកេងប្រវ័ញ្ច គ្រប់រូបភាព និងសម្រេចសក្តានុពលក្នុងជីវិតរបស់ពួកគេឲ្យបានពេញលេញ មិនថាពួកគេកើតនៅទីណា មកពីគ្រួសារដែលមានជីវភាពធូរធារឬក្រីក្រ ជាក្មេងប្រុសឬក្មេងស្រី ជាជនពិការ ឬមិនមែនពិការនោះទេ។

នេះគឺជាហេតុផលដែលបង្ហាញថាគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពជាសកលថ្មីទាំងនេះ មានសារៈសំខាន់យ៉ាងខ្លាំង។ គោលដៅទាំងនេះមានគោលបំណងធ្វើឲ្យជីវិតរបស់មនុស្សគ្រប់រូបកាន់តែមានភាពល្អប្រសើរជាងមុន ក៏ដូចជាបង្កើតនូវសង្គមដែលសម្រេចបាននូវភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចនិងសង្គមយូរអង្វែង ក្នុងបរិយាកាសមួយដែលស្អាតស្អំ មានសុវត្ថិភាព និងមានសុខសន្តិភាព។ ស្របពេលដែលឯកសារនេះនឹងបង្ហាញអ្នកឲ្យបានយល់ដឹងពីគោលដៅសកលចំនួន១៧ យើងសូមបញ្ជាក់ថាប្រទេសកម្ពុជាមានលក្ខណៈ ពិសេសដោយបានអនុម័តនូវគោលដៅទី១៨សម្រាប់ប្រទេសខ្លួន ដើម្បីដោះស្រាយបញ្ហាគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ដែលនៅតែកំពុងគំរាមកំហែងដល់សុវត្ថិភាពនិងសុខមាលភាពសហគមន៍។

យើងសង្ឃឹមថា ឯកសារនេះនឹងផ្តល់ព័ត៌មានសំខាន់ៗអំពីគោលដៅទាំងនេះ និងហេតុផលដែលមានសារៈសំខាន់ សម្រាប់អ្នកទាំងអស់គ្នា មិត្តភក្តិអ្នក គ្រួសារអ្នក ប្រទេសអ្នក និងពិភពលោកទាំងមូល។ យើងសង្ឃឹមថា ឯកសារនឹងបំផុសឲ្យអ្នកចេះឆ្ងល់បញ្ចាំងអំពីអ្វីដែលអ្នក និងមនុស្សគ្រប់គ្នាជុំវិញអ្នកអាចធ្វើបាន ដើម្បីសម្រេចគោលដៅទាំងនេះ សម្រាប់ទាំងអស់គ្នា។

ដេបូរ៉ា កូមីនី (Debora Comini)

នាយិកាអង្គការយូនីសេហ្វប្រទេសកម្ពុជា

# សេចក្តីផ្តើម

## ជូនចំពោះមិត្តគ្រប់គ្នា

យើងខ្ញុំសូមបង្ហាញជូនមិត្តទាំងអស់គ្នានូវឯកសារមគ្គុទេសក៍នេះ ដែលបង្ហាញពីគោលដៅសកលអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលរដ្ឋសមាជិកបានចាត់ទុកជាអាទិភាព សម្រាប់មនុស្សគ្រប់រូប និងភពផែនដីរបស់យើង ដើម្បីកសាងនូវពិភពលោកមួយកាន់តែល្អប្រសើរសម្រាប់ទាំងអស់គ្នា ក្នុងរយៈពេល១៥ឆ្នាំខាងមុខ។ មេដឹកនាំប្រទេសទាំងនេះបានរួមគ្នាដាក់ចេញគោលដៅទាំងនេះ ដើម្បីផ្តល់ការគាំទ្រដល់មនុស្សរាប់លាននាក់ ក៏ដូចជាអង្គការស្ថាប័នជុំវិញពិភពលោក ក្នុងនោះរាប់បញ្ចូលទាំងកុមារនិងយុវជនផងដែរ!

មគ្គុទេសក៍នេះមានគោលបំណងជួយឲ្យអ្នកយល់ច្បាស់ពីគោលដៅទាំងនេះ ថាតើវាមានឥទ្ធិពលយ៉ាងដូចម្តេចខ្លះលើជីវិតផ្ទាល់ខ្លួនអ្នក និងសកម្មភាពអ្វីខ្លះដែលអ្នកធ្វើបានជារៀងរាល់ថ្ងៃ ដើម្បីជួយឲ្យរដ្ឋាភិបាលរបស់អ្នក ធ្វើគោលដៅទាំងនេះឲ្យក្លាយជាការពិត។

គោលដៅទាំងនេះមានគោលបំណងសម្រេចឲ្យបាននូវភាពរីកចម្រើន ក្នុងការដោះស្រាយបញ្ហាធំៗ ដែលពិភពលោករបស់យើងកំពុងប្រឈមបច្ចុប្បន្ននេះ។ ប៉ុន្តែយើងអាចសម្រេចវាបាន លុះត្រាតែមានការជួយជ្រោមជ្រែងពីមនុស្សជុំវិញពិភពលោកតែប៉ុណ្ណោះ ពោលគឺមនុស្សដូចជាអ្នកទាំងអស់គ្នា គ្រួសារអ្នក លោកគ្រូអ្នកគ្រូអ្នក មិត្តភក្តិអ្នក សហគមន៍អ្នក និងបងប្អូនប្រុសស្រីអ្នក ជាដើម។ ជាការសំខាន់ណាស់ ដែលយើងទាំងអស់គ្នាត្រូវគិតពីសកម្មភាពនានាដែលយើងអាចធ្វើបាន ដើម្បីរួមចំណែកសម្រេចគោលដៅទាំងនេះ។ សូមចាំថា សូម្បីតែជំហានតូចៗក៏អាចផ្តុំគ្នា ដើម្បីសម្រេចបាននូវវឌ្ឍនភាពដ៏ធំបានដែរ ប្រសិនបើមនុស្សរាប់លាននាក់ក្នុងពិភពលោកចូលរួមជាមួយគ្នា។

ឯកសារនេះក៏ជួយយើងឲ្យយល់ពីអ្វីដែលកុមារនិងយុវជន ដូចជាអ្នកទាំងអស់គ្នា យល់ឃើញពីគោលដៅទាំងនេះ អ្វីដែលមានសារៈសំខាន់បំផុតចំពោះអ្នកទាំងអស់គ្នា ជំហានដែលគួរធ្វើដើម្បីឲ្យជីវិតមនុស្សគ្រប់រូបប្រសើរជាងមុន និងរបៀបដែលយើងទាំងអស់គ្នាអាចធ្វើការងារជាមួយគ្នា ដើម្បីជួយសម្រេចគោលដៅទាំងនេះ និងបង្កើតនូវពិភពលោកមួយកាន់តែប្រសើរសម្រាប់ថ្ងៃនេះ ក៏ដូចជាសម្រាប់អនាគត។

*យើងសង្ឃឹមថា អ្នកនឹងពេញចិត្តនឹងមគ្គុទេសក៍នេះ ហើយយើងសូមថ្លែងអំណរគុណ ចំពោះការចូលរួមរបស់អ្នក!*

The Latin America and Caribbean movement for Children

# ព័ត៌មានដែលអ្នកគួរដឹង មុនពេលដែលយើងចាប់ផ្ដើម៖

### អង្គការសហប្រជាជាតិ (UN)៖

បង្កើតឡើងក្នុងឆ្នាំ១៩៤៥ អង្គការសហប្រជាជាតិ គឺជាអង្គការអន្តរជាតិធំជាងគេ ដែលមានរដ្ឋក្នុងពិភពលោកស្ទើរតែទាំងអស់ជាសមាជិក។ អង្គការនេះមានភារកិច្ចរក្សាសន្តិភាព និងសន្តិសុខក្នុងពិភពលោក តាមរយៈការជួយដោះស្រាយបញ្ហាដែលមានផលប៉ះពាល់លើយើងទាំងអស់គ្នា លើកកម្ពស់ការគោរពសិទ្ធិមនុស្សរបស់ពលរដ្ឋគ្រប់រូប (រាប់បញ្ចូលទាំងកុមារ និងយុវជន) និងផ្ដល់ការគាំទ្រដល់បណ្ដាប្រទេសនានាឲ្យធ្វើការរួមគ្នា ដើម្បីសម្រេចបេសកកម្មនេះ។

### រដ្ឋសមាជិកអង្គការសហប្រជាជាតិ៖

ប្រទេសដែលជាសមាជិករបស់អង្គការសហប្រជាជាតិ។ ក្នុងឆ្នាំ២០១៥ មានរដ្ឋចំនួន ១៩៣ ជាសមាជិករបស់អង្គការសហប្រជាជាតិ។

### កិច្ចប្រជុំកំពូលសហស្សវត្សរ៍៖

ក្នុងឆ្នាំ២០០០ តំណាងមកពីរដ្ឋជាសមាជិក (ដែលពេលនោះមាន) ១៨៩ រដ្ឋ របស់អង្គការសហប្រជាជាតិ បានជួបប្រជុំគ្នាដើម្បីអនុម័តលើសេចក្ដីប្រកាសសហស្សវត្សរ៍។ សេចក្ដីប្រកាសនេះបានបង្កើតនូវសម្ព័ន្ធភាពសកលមួយ ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ ក្រោយកិច្ចប្រជុំនេះ គោលដៅ ដែលឥឡូវនេះត្រូវបានគេស្គាល់ថាជាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ត្រូវបានរៀបចំឡើង។

### គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍*៖

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ គឺជាគោលដៅចំនួន៨ ដែលរដ្ឋនានាបានបង្កើតឡើង ដើម្បីដឹកនាំកិច្ចខិតខំប្រែងរួមគ្នា រវាងអង្គការអន្តរជាតិនិងរដ្ឋនានា ក្នុងគោលបំណងប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រនិងគ្រោះអត់ឃ្លានក្នុងពិភពលោក ប្រឆាំងជំងឺនានាដូចជាមេរោគ/ជំងឺអេដស៍ជាដើម លើកកម្ពស់សមភាពយេនឌ័រ និងធានាឲ្យមានកុមារកាន់តែច្រើនអាចចូលរៀន រួមនឹងកិច្ចខិតខំប្រឹងប្រែងផ្សេងៗទៀតផងដែរ។

គោលដៅទាំងនេះ ត្រូវបានគ្រោងសម្រេចឲ្យបានត្រឹមឆ្នាំ២០១៥ ប៉ុន្តែទោះបីជាវឌ្ឍនភាពយ៉ាងច្រើនយ៉ាងណាក៏ដោយ ក៏នៅមានការងារជាច្រើនផ្សេងទៀតត្រូវធ្វើ។

រដ្ឋជាសមាជិកបានដាក់របាយការណ៍ទៅកាន់អង្គការសហប្រជាជាតិ តាមពេលកំណត់ ដើម្បីបង្ហាញពីអ្វីដែលខ្លួនបានធ្វើ ក្នុងការសម្រេចគោលដៅទាំងនេះ។ អង្គការសហប្រជាជាតិ ធ្វើការពិនិត្យលើវឌ្ឍនភាពដែលសម្រេចបានដោយរដ្ឋទាំងនេះ និងធ្វើការវាយតម្លៃជោគជ័យ ក្នុងការសម្រេចគោលដៅទាំងនេះ។

### គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព៖

ដោយសារគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍បញ្ចប់ក្នុងឆ្នាំ២០១៥ ពិភពលោក និងរដ្ឋាភិបាលរបស់យើង នៅតែចាំបាច់ត្រូវបន្តធ្វើការងារ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឲ្យបានពេញលេញ សម្រាប់ប្រជាពលរដ្ឋ ក៏ដូចជាដើម្បីដោះស្រាយបញ្ហាថ្មីៗ។

ឧទាហរណ៍ មនុស្សជាច្រើននាក់ក្នុងពិភពលោក ពោលគឺជាង ១ពាន់លាននាក់ បន្តរស់នៅក្នុងភាពក្រីក្រ ហើយមានមនុស្សជាច្រើននាក់ផ្សេងទៀតកំពុងប្រឈមនឹងវិសមភាព ការយកចិត្តទុកដាក់មិនស្មើភាពគ្នា និងការរើសអើង។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អង្គការសហប្រជាជាតិ បាន នឹងកំពុងពិភាក្សាអំពីអាទិភាពសកល ដែលចាំបាច់ត្រូវសម្រេចឲ្យបានក្នុងរយៈពេល១៥ឆ្នាំទៀត ពោលគឺពីឆ្នាំ២០១៦ ដល់២០៣០។ ឥឡូវនេះ គេហៅអាទិភាពទាំងនេះថាជាគោលដៅសកលសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ឬគោលដៅសកល។ មានគោលដៅសកលចំនួន១៧ គ្របដណ្ដប់លើបញ្ហាជាច្រើន ដែលមានសារៈសំខាន់សម្រាប់ពិភពលោក ដូចជាការបញ្ចប់ភាពក្រីក្រធ្ងន់ធ្ងរ ការធានាយ៉ាងណាឲ្យកុមារទាំងអស់ទទួលបានការអប់រំដែលមានគុណភាពល្អ ការសម្រេចឲ្យបាននូវឱកាសស្មើភាពគ្នាសម្រាប់ទាំងអស់គ្នា និងការលើកកម្ពស់ការអនុវត្តកាន់តែប្រសើរសម្រាប់ការប្រើប្រាស់និងផលិតកម្ម ដែលជួយឲ្យភពផែនដីទាំងមូលមានភាពស្អាតជាងមុន និងមានសុខភាពប្រសើរជាងមុន។

*ប្រសិនបើអ្នកចង់ដឹងបន្ថែមអំពីជោគជ័យនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងថាតើគោលដៅទាំងនេះស៊ីគ្នាជាមួយនឹងគោលដៅសកលថ្មីរបៀបណា យើងសូមអញ្ជើញអ្នកមើលផ្នែកឧបសម្ព័ន្ធ។ អ្នកនឹងទទួលបានព័ត៌មានសំខាន់ៗបន្ថែមទៀត។

# តើគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពមានអ្វីខ្លះ ?

*ចាប់ពីចំណុចនេះតទៅ យើងហៅគោលដៅទាំងនេះថាជា គោលដៅសកល

កាលពីខែកក្កដា ឆ្នាំ២០១៥ រដ្ឋជាសមាជិក បានសម្រេចនូវកិច្ចព្រមព្រៀងចុងក្រោយជុំវិញគោលដៅសកលនេះ។ គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីដាក់ចេញនូវកិច្ចខិតខំប្រឹងប្រែង ដើម្បីធានាយ៉ាងណាឲ្យប្រជាពលរដ្ឋក្នុងពិភពលោក អាចរស់នៅកាន់តែប្រសើរជាងមុន ដោយមិនបង្កឲ្យមានការខូចខាតដល់ភពផែនដី។ រដ្ឋត្រូវធ្វើការងារដើម្បីសម្រេចគោលដៅទាំងនេះឲ្យបានក្នុងរយៈពេល១៥ឆ្នាំខាងមុខ ពោលគឺពីឆ្នាំ២០១៥ ដល់ ២០៣០។ គោលដៅទាំងនេះ ត្រូវបានបង្កើតឡើងក្រោយពេលបញ្ចប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ត្រូវបានគេដាក់ឈ្មោះថាជា **គោលដៅអភិឌ្ឍន៍ប្រកបដោយនិរន្តរភាព។** *

# តើគោលដៅសកលនេះត្រូវបានគេជ្រើសរើសយ៉ាងដូចម្តេច ?

អង្គការសហប្រជាជាតិ បានដឹកនាំក្រុមការងារទូលាយមួយ ដែលមានសមាសភាពជាតំណាងរដ្ឋសមាជិក ហើយបានជួបប្រជុំគ្នាចំនួន១៣លើក ក្នុងឆ្នាំ២០១៣ និង ២០១៤។ ចូលរួមដោយក្រុមអ្នកជំនាញបច្ចេកទេសវិស័យអប់រំ សុខភាព អាកាសធាតុ និងប្រធានបទផ្សេងទៀត ក្រុមនេះបានធ្វើការពិភាក្សាបញ្ហាបន្ទាន់សំខាន់ៗ ដែលប្រជាពលរដ្ឋក្នុងពិភពលោកកំពុងជួបប្រទះ ហើយដែលជាបញ្ហានាំឲ្យមានការរាំងស្ទះដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋគ្រប់រូបនិងភពផែនដីទាំងមូល។ ក្នុងពេលជាមួយគ្នា ក៏មានការពិភាក្សា ជុំវិញពិភពលោកជាមួយនឹងប្រជាពលរដ្ឋធម្មតាផងដែរ ដោយផ្តល់ឲ្យពួកគេនូវឱកាសលើកឡើងនូវគំនិតពួកគេអំពីអ្វីដែលគួរមាន ក្នុងគោលដៅជាសកលនេះ។ ចេញពីការពិភាក្សាទាំងនេះ ក្រុមការងារទូលាយបានកំណត់នូវគោលដៅ និងដាក់ចេញនូវចំណុចដៅ ដែលផ្តោតលើប្រធានបទផ្សេងៗជាច្រើន។ ឧទាហរណ៍ ប្រធានបទមួយចំនួននោះរួមមាន ការបញ្ចប់ភាពក្រីក្រធ្ងន់ធ្ងរនិងគ្រោះអត់ឃ្លាន និងការធានាការគោរពសិទ្ធិមនុស្ស សន្តិភាព សមភាពយេនឌ័រ ក៏ដូចជាការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

បន្ទាប់ពីបានទទួលរបាយការណ៍ពីក្រុមការងារទូលាយនេះ រដ្ឋជាសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិ មានឱកាសពិភាក្សាសំណើដែលលើកឡើងនេះ។ រដ្ឋជាសមាជិកទាំងអស់ឯកភាពគ្នាថា អ្វីដែលក្រុមការងារទូលាយបានលើកឡើងនេះ គឺជាបញ្ជីមួយដែលមានលក្ខណៈល្អប្រសើរប្រកបដោយមហិច្ឆតា ហើយបានសម្រេចអនុម័តលើគោលដៅទាំង ១៧។ ពួកគេបានតាក់តែងនូវ "សេចក្តីប្រកាស" រួមមួយ ដើម្បីបង្ហាញគោលដៅទាំងនេះទៅកាន់ពិភពលោកទាំងមូល ក៏ដូចជាបង្ហាញពីគំនិតមួយចំនួនអំពីវិធីសាស្ត្រសម្រេចគោលដៅទាំងនេះ និងរបៀបពិនិត្យតាមដាន ក្នុងរយៈពេល១៥ឆ្នាំខាងមុខទៀត ដើម្បីពិនិត្យមើលថាមានការសម្រេចបាននូវវឌ្ឍនភាពលើគោលដៅទាំងនេះដែរឬទេ។ ជាចុងក្រោយ ក្នុងខែសីហា ឆ្នាំ២០១៥ រដ្ឋជាសមាជិកបានឯកភាពគ្នាលើរបៀបវារៈពិស្តារសម្រាប់គោលដៅថ្មី ដែលជាគោលដៅសកលសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងបានសម្តែងនូវការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីសម្រេចគោលដៅទាំងនេះនៅក្នុងកិច្ចប្រជុំមួយនៅទីស្នាក់ការកណ្តាលរបស់អង្គការសហប្រជាជាតិ នៅបុរីញូវយ៉ក កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥។

**មគ្គុទេសក៍នេះនឹងពន្យល់ពីគោលដៅសកលដែលត្រូវបានស្នើឡើង ក៏ដូចជាពីចំណុចដៅជាក់លាក់សម្រាប់គោលដៅនីមួយៗ។**

**ចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០១៥**
គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGS)



**ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០៣០**
គោលដៅអភិឌ្ឍន៍ប្រកបដោយនិរន្តរភាព

# ប៉ុន្តែតើអ្វីជាការអភិវឌ្ឍប្រកបដោយនិរន្តរភាព? ហេតុអ្វីបានជាការអភិវឌ្ឍប្រភេទនេះមានសារៈសំខាន់?



## រឿងរបស់ ចូណា

មិត្តភក្តិខ្ញុំ ចូណា រៀននៅថ្នាក់ជាមួយខ្ញុំ ហើយតែងតែ ថែទាំរបស់របររបស់នាងជានិច្ច។ នាងដឹងច្បាស់ថាឪពុក ម្តាយនាងត្រូវចំណាយលុយច្រើនប៉ុណ្ណា ដើម្បីទិញរបស់ របរទាំងនេះឲ្យនាង។ នាងស្ញប់ស្ញែងឪពុកម្តាយនាងយ៉ាង ខ្លាំង។ ឪពុកនាងជាអ្នកធ្វើស្រែចំការ ប៉ុន្តែគាត់មិនប្រើ ថ្នាំគីមីដែលបង្កគ្រោះថ្នាក់ដល់ភពផែនដីឡើយ។ គាត់ ដឹងថា ប្រសិនបើគាត់ប្រើប្រាស់ដីធ្លីរបស់គាត់មិនបាន ត្រឹមត្រូវនៅពេលនេះ ដីគាត់នឹងមិនផ្តល់ផលអ្វីសោះ ឡើយដល់គ្រួសារគាត់នាពេលអនាគត។ ម្តាយនាងពូកែ ធ្វើឈីសយ៉ាងឆ្ងាញ់ពិសារ ហើយលក់វាក្នុងតម្លៃសមរម្យ។ គ្រួសារនេះមិនមែនជាសេដ្ឋីនោះទេ ប៉ុន្តែពួកគេអាចរក ចំណូលបានល្មមរស់ដូចគេដូចឯង។ ខ្ញុំមិនដែលឃើញ ចូណា ខ្វល់ខ្វាយចង់បានទូរស័ព្ទម៉ូឌែលថ្មីនោះទេ ប៉ុន្តែ នាងតែងគិតពីអនាគតរបស់នាង និងអ្វីដែលនាងចង់ សិក្សាបន្ត បើទោះបីជានាងមិនទាន់បានសម្រេចចិត្តថា ត្រូវសិក្សាខាងផ្នែកកសិកម្មឬអប់រំក៏ដោយ។

ការអភិវឌ្ឍប្រកបដោយនិរន្តរភាព គឺជាការអភិវឌ្ឍ ដែលមានគោលបំណងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន ដោយមិនធ្វើឲ្យប៉ះពាល់ដល់ធនធាន សម្រាប់មនុស្សជំនាន់ក្រោយ។

ការអភិវឌ្ឍពុំមាននិរន្តរភាពនោះឡើយ នៅពេលដែលយើងចំណាយ ឬប្រើប្រាស់ធនធានរបស់យើងទាំងអស់នាពេលបច្ចុប្បន្ននេះ ដោយមិនបន្សល់ទុកអ្វីសោះសម្រាប់មនុស្សជំនាន់ក្រោយ។ ការអភិវឌ្ឍប្រកបដោយនិរន្តរភាពមានន័យថាជាការរីកចម្រើនទាំងអស់គ្នា ជាការគិតគូរពីមនុស្សផ្សេងទៀត និងជាការគោរពដល់បរិស្ថាន។

ដើម្បីធានាឲ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព គឺយើងចាំបាច់ត្រូវធ្វើការងាររួមគ្នា ដើម្បីធានាយ៉ាងណាឲ្យមានការផ្លាស់ប្តូរសំខាន់ៗ ក្នុងគោលបំណងបង្កើតនូវសង្គមមួយ ដែលមានយុត្តិធម៌ និងសមធម៌ជាងមុន។ ដើម្បីសម្រេចគោលដៅនេះ វាទាមទារឲ្យមានការប្តេជ្ញាចិត្តពីថ្នាក់ដឹកនាំរបស់យើងក្នុងការផ្លាស់ប្តូរនេះ ប៉ុន្តែយើងក៏ត្រូវធ្វើអ្វីដែលជាភារកិច្ចរបស់យើងផងដែរ។ ឧទាហរណ៍ យើងត្រូវផ្តល់គំនិតយោបល់អំពីបញ្ហានានា ដែលប៉ះពាល់ដល់កុមារនិងយុវជន ដោយត្រូវធ្វើការវិភាគនិងជជែកវែកញែកអំពីពិភពលោក ដែលយើងសុបិនចង់បានសម្រាប់ខ្លួនយើងនិងសម្រាប់មនុស្សជំនាន់ក្រោយ។ ក្នុងជីវិតរស់នៅផ្ទាល់ខ្លួនរបស់យើង យើងក៏ត្រូវធ្វើសកម្មភាពវិជ្ជមាន ដែលអាចរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពផងដែរ ដូចជាគោរពដល់មនុស្សផ្សេងទៀត និងដល់ភពផែនដីជាដើម។

*តើយើងចង់រស់នៅក្នុងពិភពលោកបែបណា?*
សំឡេងកុមារនិងយុវជន មានសារៈសំខាន់យ៉ាងខ្លាំង!

WORD SEARCH

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| P | O | V | E | R | T | Y | A | E | F | G | I |
| O | C | R | K | G | J | G | E | N | D | E | R |
| L | S | H | L | O | H | I | Q | B | C | D | H |
| I | Q | T | I | A | G | H | U | M | A | N | J |
| C | A | Z | M | L | F | R | I | G | T | H | S |
| I | P | U | Ñ | S | D | E | T | X | O | K | L |
| E | V | O | Y | G | H | D | Y | W | M | P | Q |
| S | P | A | R | T | I | C | I | P | A | T | E |
| W | B | C | Z | B | Y | X | S | V | A | S | Z |
| D | E | X | A | E | T | A | T | S | F | T | S |

- Child
- Goals
- Equity
- Policies
- Gender
- Poverty
- Participate
- Human Rights
- State



# សូមចំណាយពេលមួយភ្លែត...

មុននឹងយើងបន្តទៅមុខទៀត យើងសូមអញ្ជើញអ្នករីករាយស្វែងរកពាក្យ ក្នុងលំហាត់ល្បងប្រាជ្ញាស្វែងរកពាក្យនេះ។

**កុមារ (Child)**៖ បើតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ កុមារសំដៅលើជនទាំងឡាយណា ដែលមានអាយុក្រោម១៨ឆ្នាំ។

**គោលដៅ (Goals)**៖ លទ្ធផលរួម ដែលយើងចង់សម្រេចចេញពីកិច្ចខិតខំប្រឹងប្រែងរបស់យើង។ យើងដាក់ចេញនូវចំណុចដៅ ដើម្បីជួយវាស់វែងឲ្យដឹងថា យើងកំពុងសម្រេចលទ្ធផលជារួមទាំងនេះដែរឬទេ។

**សមធម៌ (Equity)**៖ វាគឺជាគន្លឹះ ដើម្បីឲ្យពិភពលោកទាំងមូលក្លាយជាកន្លែងដែលមានការអភិវឌ្ឍ មានសុខសន្តិភាព និងមានយុត្តិធម៌ជាងមុន។ សមធម៌ មានន័យថាជាការគោរព និងផ្តល់តម្លៃដល់ភាពផ្សេងៗគ្នា ដែលជាកត្តាផ្តល់លទ្ធភាពឲ្យមនុស្សគ្រប់គ្នាអាចទទួលបានឱកាសដូចគ្នា ដើម្បីការធានាឲ្យមានការគោរពសិទ្ធិរបស់ពួកគេ។

**គោលនយោបាយ (Policies)**៖ សកម្មភាពរបស់រដ្ឋ ដោះស្រាយបញ្ហានិងឆ្លើយតបចំពោះផលប្រយោជន៍ដែលពលរដ្ឋចង់បាន។

**យេនឌ័រ (Gender)**៖ អ្វីដែលកំណត់លក្ខណៈ អត្តសញ្ញាណ និងធម្មជាតិរបស់យើងម្នាក់ៗ ក្នុងនាមជាបុរស ឬជាស្ត្រី។

**ភាពក្រីក្រ (Poverty)**៖ ស្ថានភាពមួយ ដែលតម្រូវការជាមូលដ្ឋានមិនត្រូវបានបំពេញឲ្យបានគ្រប់គ្រាន់ ដូចជា លទ្ធភាពទទួលបានស្បៀងអាហារ សេវាសុខភាព ឬសេវាអប់រំ ។ល។

**ចូលរួម (Participate)**៖ វាគឺជាសិទ្ធិរបស់យើង ក្នុងការបញ្ចេញអារម្មណ៍ ស្តាប់ឮសម្តែងមតិ និងឲ្យគេយកគំនិតយោបល់របស់យើងទៅធ្វើការពិចារណា ក្នុងការសម្រេចចិត្តនានា។ ការចូលរួម មានន័យថាជាការធ្វើអ្វីមួយ នៅទីនេះនិងពេលឥឡូវនេះ។

**សិទ្ធិមនុស្ស (Human Rights)**៖ បណ្តុំសិទ្ធិ ដែលមនុស្សគ្រប់រូបត្រូវទទួលបានចាប់តាំងពីពេលកើតមក។ សិទ្ធិទាំងនេះមានមូលដ្ឋានលើគុណតម្លៃស្នូលចំនួនពីរ៖ សមភាព និងសិទ្ធិមនុស្ស។

**រដ្ឋ (State)**៖ របៀបដែលប្រទេសមួយត្រូវបានរៀបចំឡើង។ រដ្ឋមានដែនដី ប្រជាជន រដ្ឋាភិបាល និងច្បាប់ សម្រាប់តម្រង់ទិសដល់ការអនុវត្តគោលនយោបាយ និងការអនុវត្តការងាររបស់ស្ថាប័ននានា។




*គោលដៅទី១*

# គ្មានភាពក្រីក្រ

## បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង

**ដើម្បីសម្រេចគោលដៅទី១ រដ្ឋបានឯកភាព៖**

- ធានាថាមនុស្សគ្រប់គ្នាក្នុងសង្គមទទួលបានការការពារពីបញ្ហានានា ដូចជា បញ្ហាគ្មានការងារធ្វើជាដើម និងអាចទទួលបានសេវាគាំទ្រនានាដូចជា ការថែទាំសុខភាព។ នេះគឺជាអ្វីដែលគេហៅថា កិច្ចគាំពារសង្គម ដែលមានន័យជាពិសេសចំពោះការផ្តល់ការការពារ និងផ្តល់ការគាំទ្រដល់ប្រជាពលរដ្ឋក្រីក្រជាងគេ និងងាយរងគ្រោះជាងគេ។
- ធានាឲ្យមានវិភាជន៍ធនធាន សម្រាប់អនុវត្តគោលនយោបាយសង្គមនានា ដែលជួយឲ្យប្រជាពលរដ្ឋដែលមានថវិកាតិចតួច ឲ្យនៅតែមានលទ្ធភាពស្មើគ្នា ក្នុងការទទួលបានសេវាជាមូលដ្ឋាន ការងារ ដីធ្លី បច្ចេកវិទ្យា និងអាចបង្កើតក្រុមហ៊ុនដែលមានការរីកចម្រើនក្នុងសេដ្ឋកិច្ច។
- កសាងភាពធន់របស់ប្រជាពលរដ្ឋ ដែលមានថវិកាតិចតួច ដើម្បីឲ្យពួកគេកាន់តែអាចទទួលបានការការពារពីហានិភ័យធ្ងន់ធ្ងរពាក់ព័ន្ធនឹងអាកាសធាតុ ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត ក៏ដូចជាវិបត្តិសេដ្ឋកិច្ច សង្គម និងបរិស្ថានផ្សេងទៀត។

*តើហេតុអ្វីបានជាគោលដៅនេះសំខាន់សម្រាប់កុមារនិងយុវជន?*

## គោលដៅទី២

# គ្មានភាពអត់ឃ្លាន

បញ្ចប់ភាពអត់ឃ្លាន សម្រេចឲ្យបាននូវសន្តិសុខស្បៀងនិងអាហារូបត្ថម្ភប្រសើរជាងមុន និងលើកកម្ពស់កសិកម្មប្រកបដោយនិរន្តរភាព

**ដើម្បីសម្រេចគោលដៅទី២ រដ្ឋបានឯកភាព៖**

- បញ្ចប់បញ្ហាកង្វះអាហារូបត្ថម្ភ តាមរយៈការអនុវត្តកម្មវិធីសង្គមដែលមានលក្ខណៈល្អប្រសើរ សម្រាប់កុមារ មាតា និងចាស់ជរា និងធានាឲ្យមានអាហារប្រកបដោយជីវជាតិ ក្នុងបរិមាណគ្រប់គ្រាន់ពេញមួយជីវិត។
- បង្កើនផលិតកម្មកសិកម្ម និងប្រាក់ចំណូលដល់កសិករតូចតាច ជាពិសេសស្ត្រីនិងជនជាតិដើមភាគតិច ដោយគោរពបរិស្ថាន ជីវចម្រុះរបស់តំបន់នីមួយៗ និងធនធានផ្ទាល់ខ្លួនរបស់ពួកគេ។
- ចាត់វិធានការ បង្ការបញ្ហានានាមិនឲ្យកើតមានដូចជា គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងទៀត ជាដើម។
- ការពារប្រភេទគ្រាប់ពូជ ដំណាំ សត្វចិញ្ចឹម (សត្វស្រុក និងសត្វព្រៃ) និងធ្វើការបែងចែកផលដែលបានពីធនធានទាំងនេះប្រកបដោយយុត្តិធម៌។

### រឿងរបស់ផូឡា និងលូសា

ផូឡា តែងតែព្រួយបារម្ភ ពីលូសា កូនស្រីអាយុ២ឆ្នាំរបស់គាត់ ដោយនាងមានមាឌតូច និងស្គមជាងក្មេងស្រីអាយុស្របាលគ្នា។ ពួកគេរស់នៅតំបន់ភ្នំដែលមានអាកាសធាតុត្រជាក់ ដូច្នេះ ផូឡា តែងផ្តល់ទឹកសម្ល និងទឹកស៊ុបក្តៅៗឲ្យលូសាញ៉ាំ។ រហូតដល់ថ្ងៃមួយ ផូឡា បានឃើញសារអប់រំរបស់រដ្ឋាភិបាលតាមកញ្ចក់ទូរទស្សន៍ ដែលណែនាំឲ្យម្តាយផ្តល់ឲ្យកូននូវបន្លែ ស៊ុត និងសាច់ ជំនួសឲ្យទឹកសម្ល និងទឹកស៊ុប។ ចាប់តាំងពីពេលនោះមក ផូឡា បានចាប់ផ្តើមធ្វើឲ្យស្ថានភាពអាហារូបត្ថម្ភ និងសុខភាពកូនរបស់នាងកាន់តែប្រសើរជាងមុន។

*តើមានវិធានការអ្វីខ្លះត្រូវធ្វើដើម្បីធានាថាកុមារគ្រប់រូបទទួលបានអាហារមានជីវជាតិគ្រប់គ្រាន់សម្រាប់លូតលាស់ប្រកបដោយសុខភាពល្អ?*




## គោលដៅទី៣

# សុខភាពល្អ

ធានាឲ្យមានជីវិតប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពសម្រាប់មនុស្សគ្រប់គ្នា គ្រប់វ័យ

**ដើម្បីសម្រេចគោលដៅទី៣ រដ្ឋបានឯកភាព៖**

- កាត់បន្ថយមរណភាពមាតាក្នុងពេលសម្រាលកូន។
- បង្ការមរណភាពទារកទើបកើត និងកុមារអាយុក្រោម៥ឆ្នាំ។
- បញ្ឈប់ការឆ្លងរាលដាលនៃជំងឺនានា ដូចជាមេរោគ/ជំងឺអេដស៍ និងជំងឺផ្សេងទៀត ដូចជា ជំងឺរលាកថ្លើម ឬជំងឺដែលឆ្លងតាមទឹក។
- អប់រំប្រជាពលរដ្ឋអំពីការបង្ការនៃការប្រើប្រាស់គ្រឿងញៀននិងគ្រឿងស្រវឹង ក៏ដូចជាបញ្ហាសុខភាពផ្លូវចិត្ត។
- ផ្ដល់ព័ត៌មានអំពីការរៀបចំផែនការគ្រួសារ ការអប់រំផ្នែកផ្លូវភេទនិងសុខភាពបន្តពូជ។
- ធានាថាមនុស្សគ្រប់រូបមានសិទ្ធិទទួលបានសេវាសុខភាព ដូចជាការថែទាំសុខភាពដែលមានគុណភាពខ្ពស់ និងភាពងាយស្រួលក្នុងការទទួលបានឱសថ និងវ៉ាក់សាំង ក្នុងតម្លៃសមរម្យ។
- កាត់បន្ថយការស្លាប់និងរងរបួសពីគ្រោះថ្នាក់ចរាចរណ៍ទូទាំងសកលលោកឲ្យបានពាក់កណ្ដាល។
- កាត់បន្ថយចំនួនមរណភាពនិងឈឺថ្កាត់ដោយសារសារធាតុគីមីមានគ្រោះថ្នាក់ និងការបំពុលខ្យល់ ទឹក និងដី ។

*តើកុមារនិងយុវជនចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីមានសុខភាពល្អ?*

## រឿងរបស់ខាមិន

ខាមិន និងប្អូនប្រុសពីរនាក់របស់នាង មិនបានទៅរៀនឡើយ។ ពួកគេម្នាក់ៗជួយឪពុកម្តាយធ្វើការងារស្រែចម្ការ ហើយពុំមានលុយគ្រប់គ្រាន់ដើម្បីទៅរៀនទេ។ ស្ថានភាពនេះមានការផ្លាស់ប្តូរ នៅពេលរដ្ឋបានបើកសាលារៀនថ្មីមួយ ដែលផ្តល់ឲ្យពួកគេនូវការអប់រំដោយមិនគិតថ្លៃ។ កុមារទាំងអស់ក្នុងសហគមន៍របស់ពួកគេអាចទទួលបានការអប់រំដូចៗគ្នា។ មិនត្រឹមតែប៉ុណ្ណោះ ពួកគេក៏បានរៀនសូត្រអំពីគ្រាប់ពូជ បច្ចេកទេសកែលំអប្រព័ន្ធស្រោចស្រពដំណាំដាំដុះ និងជំនាញដែលមានប្រយោជន៍ផ្សេងទៀត។ ជារួម គឺនៅសាលារៀនគ្រប់គ្នាទទួលបានយកចិត្តទុកដាក់ស្មើគ្នា មិនថាពួកគេជាក្មេងស្រីឬក្មេងប្រុស មកពីគ្រួសារមានជីវភាពធូរធារឬក្រីក្រនោះទេ។ គ្រប់គ្នាមានសិទ្ធិទទួលបានការអប់រំដូចគ្នា។

គោលដៅទី៤

# ការអប់រំប្រកបដោយគុណភាព

ធានាឲ្យមានការអប់រំប្រកបដោយគុណភាពជាបរិយាប័ន្ននិងដោយសមធម៌ ព្រមទាំងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់មនុស្សគ្រប់រូប

ដើម្បីសម្រេចគោលដៅទី៤ រដ្ឋបានឯកភាព៖

- ធានាឲ្យមានការអប់រំ សម្រាប់ទាំងអស់គ្នា ដោយចាប់ផ្តើមពីការអប់រំថ្នាក់មូលដ្ឋាន។
- ផ្តល់ឱកាសបន្ថែមដល់យុវជន និងមនុស្សពេញវ័យទទួលបានការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីឲ្យពួកគេអាចទទួលបានការងារធ្វើកាន់តែប្រសើរជាងមុន។
- បញ្ចប់បញ្ហាវិសមភាពនៃឱកាសទទួលបានការអប់រំរវាងបុរសនិងស្ត្រី កុមារពិការ ជនជាតិដើមភាគតិច និងជនរងគ្រោះដោយសារជម្លោះនានា។
- កែលំអសម្ភារសិក្សានៅតាមសាលារៀន ដើម្បីបង្កើតនូវបរិយាកាសប្រកបដោយសុវត្ថិភាព និងវិជ្ជមានសម្រាប់មនុស្សគ្រប់គ្នា។
- បង្កើនចំនួនអាហារូបករណ៍សម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងប្រទេសឬក្រៅប្រទេស។
- បង្កើនចំនួនគ្រូទទួលបានការបណ្តុះបណ្តាល និងមានសមត្ថភាពត្រឹមត្រូវ។
- លើកកម្ពស់ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

*តើកត្តាចាំបាច់អ្វីខ្លះ ដើម្បីឲ្យកុមារនិងមនុស្សវ័យក្មេងគ្រប់រូបទទួលបានការអប់រំល្អ?*

# គោលដៅទី៥
# សមភាពយេនឌ័រ

សម្រេចឲ្យបានសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រី និងក្មេងស្រីគ្រប់រូប

ដើម្បីសម្រេចគោលដៅទី៥ រដ្ឋបានឯកភាព៖

- បញ្ចប់រាល់ទម្រង់នៃការរើសអើងលើស្ត្រីនិងក្មេងស្រីគ្រប់រូប នៅគ្រប់ទិសទី។
- បញ្ចប់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី រាប់បញ្ចូលទាំងការជួញដូរផ្លូវភេទ និងការកេងប្រវ័ញ្ចក្នុងទម្រង់ផ្សេងទៀត។
- បញ្ចប់ការអនុវត្តនិងប្រពៃណីណាដែលអាចប៉ះពាល់ដល់សុខភាពផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទរបស់ស្ត្រីនិងក្មេងស្រី។
- ទទួលស្គាល់ និងផ្តល់តម្លៃដល់ការងាររបស់ស្ត្រីក្នុងផ្ទះ។ លើកទឹកចិត្តឲ្យស្ត្រីនិងក្មេងស្រី មានឱកាសស្មើភាពគ្នា ដើម្បីឲ្យពួកគេអាចបញ្ចេញមតិ និងមានឱកាសពិតប្រាកដ ដើម្បីចូលរួមក្នុងគ្រប់សកម្មភាពនយោបាយ សេដ្ឋកិច្ច និងសកម្មភាពសាធារណៈនានា។
- ការពារសិទ្ធិស្ត្រីក្នុងការទទួលបានសេវាថែទាំសុខភាពផ្លូវភេទនិងបន្តពូជ។
- លើកកម្ពស់គោលនយោបាយនិងច្បាប់ ដើម្បីធានាសមភាពយេនឌ័រ រួមទាំងធ្វើកំណែទម្រង់នានា ដើម្បីផ្តល់ឲ្យស្ត្រីនូវលទ្ធភាពដូចៗគ្នា ក្នុងការទទួលបានកម្មសិទ្ធិ និងគ្រប់គ្រងលើដីធ្លី ក៏ដូចជាទ្រព្យសម្បត្តិក្នុងទម្រង់ផ្សេងទៀត សេវាហិរញ្ញវត្ថុ មរតក និងធនធានធម្មជាតិនានា។




*តើហេតុអ្វីបានជាការដែលកុមារីនិងកុមារាអាចធ្វើអ្វីៗបានដូចគ្នាជារឿងសំខាន់?*

# គោលដៅទី៦
# ទឹកស្អាតនិងអនាម័យ

ធានាឲ្យមានទឹកនិងការគ្រប់គ្រងទឹក និងសេវាអនាម័យប្រកបដោយនិរន្តរភាព សម្រាប់មនុស្សគ្រប់រូប

ដើម្បីសម្រេចគោលដៅទី៦ រដ្ឋបានឯកភាព៖

- ធានាថាមនុស្សគ្រប់គ្នាមានទឹកស្អាតប្រើប្រាស់។
- ធានាថាមនុស្សគ្រប់គ្នាអាចទទួលបានសេវាអនាម័យ (ការបង្ហូរទឹកសំណល់ឲ្យមានសុវត្ថិភាព និងគ្រប់គ្រងកាកសំណល់ឲ្យបានល្អ) និងការអប់រំសាធារណជនទូទៅអំពីទម្លាប់ល្អលើអនាម័យនិងសុខភាព។
- ពិនិត្យតាមដានគុណភាពទឹក ដើម្បីកាត់បន្ថយភាពកខ្វក់។ ការពារមិនឲ្យសារធាតុគីមី ឬសារធាតុបំពុល ហូរចូលទៅក្នុងទឹក។
- កែលំអការប្រើប្រាស់ទឹក ដោយបង្កើនធនធានកែច្នៃប្រើប្រាស់ឡើងវិញ។
- បង្កើនការយល់ដឹងដល់សហគមន៍ ដើម្បីធានាឲ្យបំពេញតួនាទីសកម្មក្នុងការលើកកម្ពស់ការគ្រប់គ្រងទឹកនិងអនាម័យរបស់ពួកគេ។
- ការពារ និងស្តារឡើងវិញនូវប្រព័ន្ធបរិស្ថាន ដែលពាក់ព័ន្ធជាមួយនឹងធនធានទឹក ដូចជា ភ្នំ ព្រៃឈើ ដីសើម ទន្លេ ជលសិលា និងបឹងបួរនានា។

## រឿងរបស់ម៉ាធា

ម៉ាធានិងក្មេងស្ទើរតែគ្រប់គ្នាក្នុងសហគមន៍មានជំងឺ។ មនុស្សពេញវ័យក៏មានបញ្ហាសុខភាពមួយចំនួនផងដែរ។ នៅពេលពួកគេទៅមណ្ឌលសុខភាពនៅជិតបំផុត វេជ្ជបណ្ឌិតបាននិយាយថា ដោយសារគ្រប់គ្នាមានរោគសញ្ញាដូចគ្នា មូលហេតុដែលនាំឲ្យមានបញ្ហាសុខភាពទាំងនេះកើតមានឡើង គឺប្រហែលមកពីទឹកដែលគេផឹកទាំងសុីទេនៗជារៀងរាល់ពីរថ្ងៃម្តង។ តាមពិត ទឹកនៅទីនេះមានភាពកខ្វក់ ហើយដោយសារមានអ្នកភូមិតិចនាក់ណាស់ មានចង្ក្រានហ្គាស ប្រើប្រាស់ ពួកគេមិនអាចដាំទឹកសម្រាប់ផឹក ឬយកទៅចម្អិនម្ហូបបានឡើយ។



*តើអ្នកប្រើទឹកក្នុងសកម្មភាពសំខាន់ជាងគេណាខ្លះ? ចុះប្រសិនបើអត់ទឹកវិញ អ្នកនឹងធ្វើដូចម្តេច? តើយើងអាចធ្វើដូចម្តេចដើម្បីធានាថាកុមារនិងមនុស្សវ័យក្មេងគ្រប់រូបមានទឹកស្អាតប្រើប្រាស់?*




## គោលដៅទី៧

# ថាមពលកកើតឡើងវិញ

ធានាឲ្យមានការទទួលបានថាមពលក្នុងតម្លៃសមរម្យ ទុកចិត្តបាន មាននិរន្តរភាព និងទំនើប សម្រាប់មនុស្សគ្រប់រូប

ដើម្បីសម្រេចគោលដៅទី៧ រដ្ឋបានឯកភាព៖

- ធានាថាមនុស្សគ្រប់គ្នាអាចទទួលបានសេវាថាមពលទំនើបក្នុងតម្លៃសមរម្យ និងអាចជឿទុកចិត្តបាន តាមរយៈហេដ្ឋារចនាសម្ព័ន្ធថ្មី និងបច្ចេកវិទ្យាល្អប្រសើរជាងមុន។
- លើកកម្ពស់ប្រសិទ្ធភាពថាមពល ដោយពន្លឿនការអភិវឌ្ឍបច្ចេកវិទ្យាដែលកាត់បន្ថយការខ្ជះខ្ជាយថាមពល។
- បង្កើនការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញក្នុងសកលលោក ធៀបជាមួយនឹងប្រភពថាមពលផ្សេងទៀត។
- សហការគ្នាស្រាវជ្រាវនិងអភិវឌ្ឍធនធានថាមពលកកើតឡើងវិញនិងថាមពលស្អាតផ្សេងទៀត។

*តើមានរបស់របរណាខ្លះ ដែលប្រើប្រាស់នៅផ្ទះ ឬនៅសាលារៀន ដែលត្រូវការអគ្គិសនី ដែរឬទេ? ហេតុអ្វីបានជាកុមារ និងយុវជនទាំងអស់ចាំបាច់ត្រូវមានអគ្គិសនីប្រើប្រាស់?*

## គោលដៅទី៨

# ការងារសមរម្យនិងកំណើនសេដ្ឋកិច្ច

លើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ននិងនិរន្តរភាព និងមុខរបរពេញលេញនិង ប្រកបដោយផលិតភាព និងការងារសមរម្យសម្រាប់មនុស្សគ្រប់រូប




ដើម្បីសម្រេចគោលដៅទី៨ រដ្ឋបានឯកភាព៖

- ផ្តល់ឱកាសការងារមានសុវត្ថិភាព ប្រកបដោយភាពច្នៃប្រឌិត ដែលលើកទឹកចិត្តឲ្យមនុស្សមានការអភិវឌ្ឍ។
- ធានាឲ្យមានការគោរព និងការពារធនធានធម្មជាតិនៅរាល់សកម្មភាពសេដ្ឋកិច្ចនានា។
- លើកកម្ពស់ការងារសមរម្យ និងបរិយាកាសការងារប្រកបដោយសុវត្ថិភាពសម្រាប់បុរសនិងស្ត្រីគ្រប់រូប សម្រាប់យុវជន ជនពិការ និងពលករចំណាកស្រុក។
- កាត់បន្ថយចំនួនយុវជនពុំមានការងារធ្វើ តាមរយៈការបង្កើនឱកាសទទួលបានការបណ្តុះបណ្តាល។
- ទប់ស្កាត់ និងបញ្ចប់រាល់ទម្រង់នៃការបង្ខំលើកម្លាំងពលកម្ម និងពលកម្មកុមារ។
- ចាត់វិធានការរួមគ្នាក្នុងសកលលោក ដើម្បីបង្កើតការងារឲ្យបានកាន់តែច្រើនសម្រាប់យុវជន។

*តើហេតុអ្វីបានវាជារឿងសំខាន់ ដែលមនុស្សអាចរកការងារល្អធ្វើបាន? តើកត្តាអ្វីខ្លះ ដែលអាចរារាំងមនុស្សមួយចំនួនមិនអាចរកការងារបានល្អធ្វើ និងតើយើងអាចធ្វើអ្វីខ្លះដើម្បីឲ្យមនុស្សគ្រប់គ្នាកាន់តែអាចរកការងារល្អបានធ្វើ?*

## គោលដៅទី៩

# ការបង្កើតថ្មីនិងហេដ្ឋារចនាសម្ព័ន្ធ




កសាងហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់ លើកកម្ពស់ឧស្សាហភាវូបនីយកម្មបែបបរិយាប័ន្ននិងប្រកបដោយនិរន្តរភាព និងជម្រុញឲ្យមានការបង្កើតថ្មី

ដើម្បីសម្រេចគោលដៅទី៩ រដ្ឋបានឯកភាព៖

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលធន់ជាប់បានយូរ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសុខុមាលភាពរបស់មនុស្ស។
- ផ្តល់ឲ្យសហគ្រាសតូចៗនូវឱកាសទទួលបានឥណទាន និងការគាំទ្របច្ចេកទេស សម្រាប់ការអភិវឌ្ឍ។
- ធានាថាក្រុមហ៊ុននានាខិតខំជម្រុញឲ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងមិនបង្កគ្រោះថ្នាក់ដល់បរិស្ថាន។
- បែងចែកធនធានសម្រាប់ការស្រាវជ្រាវ ដើម្បីឆ្លើយតបចំពោះតម្រូវការជាក់លាក់របស់ប្រទេស និងធ្វើឲ្យបច្ចេកវិទ្យាកាន់តែមានភាពល្អប្រសើរជាងមុន។
- ធានាថាមនុស្សគ្រប់រូបមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិត និងបច្ចេកវិទ្យាថ្មីៗ ជាពិសេសអ្នកដែលរស់នៅក្នុងប្រទេសដែលមានការអភិវឌ្ឍតិចតួច។

*តើអ្នកជឿថាថ្នាក់ដឹកនាំរដ្ឋាភិបាលនិងធុរកិច្ច អាចធ្វើអ្វីៗបន្ថែមទៀត ដើម្បីបរិស្ថាន និងបុគ្គលិករបស់ពួកគេដែរឬទេ?*

*គោលដៅទី១០*

# កាត់បន្ថយវិសមភាព

## កាត់បន្ថយវិសមភាពនៅក្នុង និងរវាងប្រទេសនានា

**ដើម្បីសម្រេចគោលដៅទី១០ រដ្ឋបានឯកភាព៖**

- ផ្តល់ការគាំទ្រដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងភាពក្រីក្រ ដើម្បីឲ្យពួកគេអាចទទួលបានការគាំទ្រ ឲ្យមានកំណើនសេដ្ឋកិច្ចឆាប់រហ័ស និងប្រកបដោយនិរន្តរភាព។
- ធានាថា ច្បាប់និងការអនុវត្តនានា មិនរើសអើងប្រឆាំងនឹងក្រុមណាឡើយ ប៉ុន្តែស្តាប់តម្រូវការនិងគំនិតយោបល់នានារបស់អ្នកទទួលរងផលប៉ះពាល់។
- ធានាថាច្បាប់និងកម្មវិធីសង្គមនានា ផ្តល់ការការពារដល់ជនជួបការលំបាកនិងរងផលប៉ះពាល់។ ឧទាហរណ៍ នៅពេលកំណត់កូតា ក្នុងគណបក្សនយោបាយ ត្រូវបញ្ចូលយុវជន ស្ត្រី ជនជាតិដើមភាគតិច និងជនពិការផងដែរ។
- ធានាថាប្រជាពលរដ្ឋដែលបានចាកចេញពីប្រទេសមួយទៅរស់នៅក្នុងប្រទេសមួយទៀត ទទួលអត្ថប្រយោជន៍ពីច្បាប់ដើម្បីការពារពួកគេនៅទីនោះ។




*តើអ្នកធ្លាប់មានអារម្មណ៍ថាត្រូវបានគេផាត់ចេញដែរឬទេ? តើអ្នកធ្លាប់កត់សម្គាល់ឃើញ នៅពេលដែលអ្វីៗហាក់បីដូចជាមិនយុត្តិធម៌ សម្រាប់មនុស្សមួយចំនួនដែរឬទេ? តើវាធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងដូចម្តេច និងតើអ្នកគិតថាអ្វីខ្លះគួរតែធ្វើ ដើម្បីឲ្យមានភាពយុត្តិធម៌ជាងមុន?*

## គោលដៅទី១១

# ទីក្រុងនិងសហគមន៍មាននិរន្តរភាព

ធ្វើឲ្យទីក្រុង និងកន្លែងតាំងទីលំនៅរបស់មនុស្សមានលក្ខណៈបរិយាប័ន្ន សុវត្ថិភាព ធន់ និងមាននិរន្តរភាព




ដើម្បីសម្រេចគោលដៅទី១១ រដ្ឋបានឯកភាព៖

- ធានាថាគ្រប់គ្នាអាចទទួលបានលំនៅដ្ឋានប្រកបដោយគុណភាព សុវត្ថិភាព និងមានសេវាមូលដ្ឋាននានា។
- ផ្ដល់មធ្យោបាយធ្វើដំណើរដែលមានសុវត្ថិភាព មានការរៀបចំបានល្អ ដែលមិនបង្កគ្រោះថ្នាក់ដល់បរិស្ថាន ហើយត្រូវបានរៀបចំជាពិសេស សម្រាប់កុមារ ស្ត្រី និងជនងាយរងគ្រោះ។
- ជម្រុញឲ្យមានការចូលរួមពីសហគមន៍ ក្នុងការពិភាក្សា និងរៀបចំផែនការសម្រាប់កែលំអទីក្រុងរបស់ពួកគេ។
- ពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីការពារ និងគាំពារដល់បេតិកភ័ណ្ឌវប្បធម៌ និងធម្មជាតិ។
- បង្កើនភាពធន់ទៅនឹងគ្រោះមហន្តរាយនានា។
- ធានាឲ្យមានការពិនិត្យតាមដានលើការគ្រប់គ្រងកាកសំណល់ និងគុណភាពទឹក។
- រៀបចំសហគមន៍ឲ្យចេះគ្រប់គ្រងធនធានរបស់ខ្លួនឲ្យបានត្រឹមត្រូវ និងដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ។

*តើមានកត្តាអ្វីខ្លះ ដែលធ្វើឲ្យទីក្រុងរបស់យើងមានសុវត្ថិភាព និងកាន់តែមានភាពល្អប្រសើរ សម្រាប់កុមារ និងយុវជន?*



# គោលដៅទី១២

# ការប្រើប្រាស់ប្រកបដោយមានទំនួលខុសត្រូវ




### ធានាឲ្យមានការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព

**ដើម្បីសម្រេចគោលដៅទី១២ រដ្ឋបានឯកភាព៖**

- កាត់បន្ថយបរិមាណនៃការខ្ជះខ្ជាយអាហារសម្រាប់មនុស្សម្នាក់ៗក្នុងពិភពលោក ឲ្យបានពាក់កណ្ដាល ដោយបុគ្គលនិងក្រុមហ៊ុននានា។
- ធានាឲ្យមានការបំពេញកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងអន្តរជាតិនានា ពាក់ព័ន្ធនឹងការទុកដាក់ និងប្រើប្រាស់សារធាតុគីមី ដើម្បីខ្យល់ ទឹក និងដី។
- កាត់បន្ថយការបង្កើតសំណល់ តាមរយៈសកម្មភាពចំនួន ៣៖ កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃសម្រាប់ប្រើប្រាស់ឡើងវិញ។
- ធានាថាក្រុមហ៊ុនធំៗធ្វើសកម្មភាពរបស់ខ្លួនប្រកបដោយទំនួលខុសត្រូវ បើកចំហ និងផ្ដល់ភាពល្អប្រសើរដល់បរិស្ថាន។
- ផ្ដល់ព័ត៌មាននិងការអប់រំដល់សាធារណជនទូទៅ និងផ្ដល់មធ្យោបាយ ដើម្បីឲ្យពួកគេ អាចរស់នៅប្រកបដោយភាពសុខដុមរមនាជាមួយនឹងធម្មជាតិ សំដៅធានានិរន្តរភាពនៃការរស់នៅរបស់ពួកគេ។

*តើមានរឿងតូចៗអ្វីខ្លះ ដែលអ្នកអាចធ្វើបាន ក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក ដែលអាចជួយមិនឲ្យមានការខ្ជះខ្ជាយធនធាន ដូចជា ទឹក អាហារ ដើមឈើ និងថាមពលជាដើម?*




*គោលដៅទី១៣*

# សកម្មភាពបរិស្ថាន

ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា

**ដើម្បីសម្រេចគោលដៅទី១៣ រដ្ឋបានឯកភាព៖**

- ធានាថាមនុស្សអាចត្រៀមរៀបចំខ្លួនបានល្អគ្រប់គ្រាន់ សម្រាប់មុខសញ្ញាគ្រោះថ្នាក់ពាក់ព័ន្ធនឹងអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិនានា។
- បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុ ទៅក្នុងរបៀបវារៈរដ្ឋាភិបាលរបស់ខ្លួននិងវិភាជធនធាន ដើម្បីប្រយុទ្ធនឹងការប្រែប្រួលអាកាសធាតុ។

*ហេតុអ្វីបានជាការប្រែប្រួលអាកាសធាតុ មានសារៈសំខាន់សម្រាប់កុមារនិងយុវជន? តើអ្នកអាចជួបប្រទះនឹងផលប៉ះពាល់អ្វីខ្លះ?*

## គោលដៅទី១៤

# ជីវិតក្រោមទឹក

អភិរក្ស និងប្រើប្រាស់មហាសាគរ សមុទ្រ និងធនធានសមុទ្រប្រកបដោយនិរន្តរភាព សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព



ដើម្បីសម្រេចគោលដៅទី១៤ រដ្ឋបានឯកភាព៖

- កាត់បន្ថយការបំពុលជីវិតក្រោមសមុទ្រត្រឹមឆ្នាំ២០២៥ ដោយសារតែការបំពុលភាគច្រើន គឺមានប្រភពចេញពីសកម្មភាពលើដីរបស់មនុស្ស។
- អនុម័តច្បាប់ហាមឃាត់ការនេសាទខុសច្បាប់ ការនេសាទលើសកម្រិត និងការនេសាទបែបបំផ្លិចបំផ្លាញផ្សេងទៀត។
- ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ដល់ប្រទេសក្រីក្រជាងគេនិងកោះតូចៗ ដើម្បីឲ្យមានការការពារនិងការគ្រប់គ្រងធនធានសមុទ្រកាន់តែប្រសើរជាងមុននិងដោយគិតគូរពីអនាគត។

*តើមានវត្ថុសំខាន់អ្វីខ្លះ ដែលយើងប្រើប្រាស់និងរកបានក្នុងសមុទ្រ? ហេតុអ្វីបានជាវារឿងសំខាន់ ដែលត្រូវមានការការពារវត្ថុទាំងនោះ?*



## គោលដៅទី១៥

# ជីវិតលើដី

ការពារ ស្តារ និងជម្រុញការប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ី ដែនដីគោកដោយនិរន្តរភាព គ្រប់គ្រង ព្រៃឈើដោយនិរន្តរភាព ប្រយុទ្ធនឹងឱនភាពដី និងបញ្ឈប់ ព្រមទាំងបង្វែរទិសនៃការរេចរឹលគុណភាពដី និងបញ្ឈប់ការបាត់បង់ជីវៈចម្រុះ

**ដើម្បីសម្រេចគោលដៅទី១៥ រដ្ឋបានឯកភាព៖**

- ការពារនិងអភិរក្សប្រព័ន្ធអេកូឡូស៊ី ( ឧទាហរណ៍ វាលខ្សាច់ និងព្រៃឈើ ) ដោយគោរពតាមកិច្ចព្រមព្រៀងអន្តរជាតិ ដែលបានចុះហត្ថលេខា។
- កាត់បន្ថយការបាត់បង់ព្រៃឈើ និងដាំដើមឈើឡើងវិញ ដើម្បីបង្កើតព្រៃឈើសារជាថ្មី។
- ការពារ និងទប់ស្កាត់ជាបន្ទាន់នូវការផុតពូជសត្វដែលកំពុងប្រឈមនឹងគ្រោះថ្នាក់ បញ្ឈប់ការបរបាញ់ដោយគ្មានការត្រួតពិនិត្យត្រឹមត្រូវ និងជួញដូរពពួកសត្វ និងរុក្ខជាតិដែលត្រូវបានការពារ។ វាជាការសំខាន់ណាស់ដែលត្រូវជម្រុញឲ្យមានការចូលរួមពីសហគមន៍ជនជាតិដើមភាគតិច។



*តើវាជាការសំខាន់ដែរឬទេដែលត្រូវមានរុក្ខជាតិនិងសត្វចម្រុះគ្រប់ប្រភេទនៅជុំវិញពិភពលោក? តើកុមារអាចធ្វើអ្វីខ្លះ ដើម្បីជួយការពាររុក្ខជាតិ និងសត្វទាំងនេះក៏ដូចជាទីជម្រករបស់វា?*




*គោលដៅទី១៦*

# សន្តិភាពនិងយុត្តិធម៌

លើកកម្ពស់សង្គមសន្តិភាពនិងបរិយាប័ន្ន ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព ផ្តល់យុត្តិធម៌ដល់មនុស្សគ្រប់រូប និងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ន នៅគ្រប់លំដាប់ថ្នាក់

ដើម្បីសម្រេចគោលដៅទី១៦ រដ្ឋបានឯកភាព៖

- បញ្ចប់អំពើហិង្សាក្នុងពិភពលោកទាំងមូល និងមរណភាពដែលពាក់ព័ន្ធនឹងអំពើហិង្សា។
- បញ្ចប់ការរំលោភបំពាន ការកេងប្រវ័ញ្ច ការជួញដូរ និងរាល់ទម្រង់នៃអំពើហិង្សានិងការធ្វើទារុណកម្មលើកុមារ។
- ធានាថាមនុស្សគ្រប់គ្នា មានលទ្ធភាពដូចគ្នា ក្នុងការទទួលបានយុត្តិធម៌ ក្នុងប្រទេសរបស់ពួកគេ ឬក្នុងប្រទេសផ្សេងទៀត។
- ប្រយុទ្ធនឹងបទឧក្រិដ្ឋនិងអំពើពុករលួយ ក្នុងគ្រប់ទម្រង់។
- កែលំអស្ថាប័នរដ្ឋនានា ដែលនាំឲ្យមានការបង្កើនទំនុកចិត្តដល់ប្រជាពលរដ្ឋ។
- ធានាឲ្យមានកិច្ចពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋ ហើយរដ្ឋាភិបាលធ្វើការសម្រេចចិត្ត ដោយគិតគូរពីប្រយោជន៍របស់កុមារ និងមនុស្សពេញវ័យ។ ឧទាហរណ៍ ត្រូវមានការពិគ្រោះយោបល់ជាមួយកុមារនិងយុវជន មុនពេលមានការចុះហត្ថលេខាអនុម័តច្បាប់ណាមួយ ដែលមានផលប៉ះពាល់លើជីវិតរបស់ពួកគេ។
- ធានាយ៉ាងណាឲ្យកុមារគ្រប់រូបទទួលបានអត្តសញ្ញាណ រួមទាំងការចុះសំបុត្រកំណើតផង។
- ធានាថាមនុស្សគ្រប់រូបអាចមានសេរីភាព ក្នុងការទទួលបានព័ត៌មាននានា។
- ពង្រឹងស្ថាប័ន ដើម្បីទប់ស្កាត់អំពើហិង្សា អំពើភេរវកម្ម និងបទល្មើសនានា។

*ហេតុអ្វីជារឿងសំខាន់ ដែលកុមារនិងយុវជន ត្រូវមានអារម្មណ៍ថាខ្លួនមានសុវត្ថិភាពនៅក្នុងផ្ទះ និងសាលារៀនរបស់ខ្លួន? តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីជួយលើកកម្ពស់សុវត្ថិភាពកុមារក្នុងសហគមន៍របស់អ្នក? តើគេអាចធ្វើអ្វីខ្លះ ដើម្បីឲ្យអ្នកអាចរស់នៅក្នុងពិភពលោកដែលមានសុវត្ថិភាពជាងមុន និងមានអំពើហិង្សាតិចជាងមុន?*

## គោលដៅទី១៧

# ភាពជាដៃគូដើម្បីសម្រេចគោលដៅទាំងនេះ




ពង្រឹងមធ្យោបាយអនុវត្ត និងបង្កើនភាពរស់រវើកនៃភាពជាដៃគូសកល សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព

ដើម្បីសម្រេចគោលដៅទាំងនេះ រដ្ឋបានឯកភាព៖

- ជួយធានាថាគ្រប់ប្រទេស អាចសម្រេចគោលដៅទាំងនេះត្រឹមឆ្នាំ២០៣០។ គោលដៅជាសកលទាំងនេះ គួរបញ្ចូលទៅក្នុងផែនការជាតិ ហើយរដ្ឋនីមួយៗត្រូវធ្វើការសម្រេចចិត្តថាតើបញ្ហាណាខ្លះជាអាទិភាពបន្ទាន់ក្នុងប្រទេសរបស់ខ្លួន។
- ធានាថាឲ្យរដ្ឋនីមួយៗធ្វើការវិភាជន៍ធនធានរបស់ខ្លួន ដើម្បីសម្រេចគោលដៅទាំងនេះ។ លើសពីនេះ ប្រទេសអភិវឌ្ឍគួរប្តេជ្ញាគាំទ្រឲ្យមានការសម្រេចគោលដៅទាំងនេះ នៅតាមប្រទេសមានការអភិវឌ្ឍតិចតួច។
- គោរពការសម្រេចចិត្តគោលនយោបាយរបស់ប្រទេសនានា ដរាបណាការសម្រេចចិត្តទាំងនោះមានសង្គតិភាពជាមួយគ្នា។ ឧទាហរណ៍ អ្នកមិនអាចបង្កើតនូវវិធានសម្រាប់ការពារធនធានធម្មជាតិ ហើយក្នុងពេលជាមួយគ្នាផ្តល់ការអនុញ្ញាតឲ្យមានការធ្វើអាជីវកម្មលើធនធានទាំងនោះបានឡើយ។
- ជម្រុញឲ្យមានការចូលរួមពីអង្គការស្ថាប័ន និងបុគ្គលនានា ដែលបាននឹងកំពុងធ្វើការងារជាច្រើនឆ្នាំមកហើយជុំវិញប្រធានបទនានាដែលពាក់ព័ន្ធជាមួយនឹងគោលដៅជាសកលទាំងនេះ។ អង្គការស្ថាប័ននិងបុគ្គលទាំងនេះគួរត្រូវបានជម្រុញឲ្យចូលរួម ក្នុងការងារទាំងឡាយ ដែលនាំឲ្យមានការសម្រេចគោលដៅទាំងនេះ ដោយសារតែបទពិសោធ និងការគាំទ្ររបស់ពួកគេគឺមានការចាំបាច់។
- ធានាថារដ្ឋធ្វើការកែលំអរបៀបគ្រប់គ្រងទិន្នន័យ និងស្ថិតិរបស់ខ្លួន ដើម្បីអាចវាយតម្លៃលើវឌ្ឍនភាព ក្នុងការឈានទៅសម្រេចគោលដៅសកលទាំងនេះ។

# ឥឡូវនេះ អ្នកបានដឹងពីគោលដៅទាំងអស់ហើយ សូមភ្ជាប់គោលដៅនីមួយៗនឹងរូបសញ្ញាឲ្យបានត្រូវគ្នា។

| | |
|---|---|
| គោលដៅទី ១ | គ្មានភាពក្រីក្រ |
| គោលដៅទី ២ | គ្មានគ្រោះអត់ឃ្លាន |
| គោលដៅទី ៣ | សុខភាពល្អ |
| គោលដៅទី ៤ | ការអប់រំប្រកបដោយគុណភាព |
| គោលដៅទី ៥ | សមភាពយេនឌ័រ |
| គោលដៅទី ៦ | ទឹកស្អាត និងអនាម័យ |
| គោលដៅទី ៧ | ថាមពលកកើតឡើងវិញ |
| គោលដៅទី ៨ | ការងារសមរម្យនិងកំណើនសេដ្ឋកិច្ច |
| គោលដៅទី ៩ | ការបង្កើតថ្មីនិងហេដ្ឋារចនាសម្ព័ន្ធ |
| គោលដៅទី ១០ | កាត់បន្ថយវិសមភាព |
| គោលដៅទី ១១ | ទីក្រុងនិងសហគមន៍មាននិរន្តរភាព |
| គោលដៅទី ១២ | ការប្រើប្រាស់ប្រកបដោយទំនួលខុសត្រូវ |
| គោលដៅទី ១៣ | សកម្មភាពអាកាសធាតុ |
| គោលដៅទី ១៤ | ជីវិតក្រោមទឹក |
| គោលដៅទី ១៥ | ជីវិតលើដី |
| គោលដៅទី ១៦ | សន្តិភាពនិងយុត្តិធម៌ |
| គោលដៅទី ១៧ | ភាពជាដៃគូដើម្បីសម្រេចគោលដៅ |



# សូមអរគុណចំពោះការចូលរួម

មុននឹងយើងលាគ្នា សូមពិភាក្សាជាក្រុម៖

*តើគោលដៅអ្វីខ្លះដែលអ្នកគិតថាមានសារៈសំខាន់បំផុតសម្រាប់កុមារនិងយុវជន?*
*សូមរៀបគោលដៅទាំងនេះ ទៅតាមលំដាប់នៃអាទិភាព។*

១ ..........................................................................................

២ ..........................................................................................

៣ ..........................................................................................

៤ ..........................................................................................

៥ ..........................................................................................



តើគោលដៅណាខ្លះ ដែលអ្នកនឹងខិតខំចូលរួមធ្វើឲ្យសម្រេច ហើយតើអ្នកនឹងធ្វើសកម្មភាពអ្វីខ្លះ?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................



ឧបសម្ព័ន្ធ

# គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) និងចំណុចដៅ

## គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ពីឆ្នាំ២០០០ ដល់២០១៥៖

តើ MDGs មានទំនាក់ទំនងយ៉ាងដូចម្ដេចជាមួយនឹងគោលដៅជាសកលថ្មីនេះ? សូមគូសបន្ទាត់ភ្ជាប់ MDGs ដែលអ្នកគិតថាត្រូវគ្នាជាមួយនឹងគោលដៅជាសកល?

**MDG ទី១**
លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និងគ្រោះអត់ឃ្លាន

**វឌ្ឍនភាព៖** ភាគរយនៃមនុស្ស ដែលមានចំណូលតិចជាង ១,២៥ ដុល្លារ ក្នុងមួយថ្ងៃ ត្រូវបានកាត់បន្ថយបានពាក់កណ្ដាល។

**MDG ទី២**
សម្រេចឲ្យបានការអប់រំបឋមសិក្សាជាសកល

**វឌ្ឍនភាព៖** ការចុះឈ្មោះចូលរៀននៅបឋមសិក្សា នៅតាមប្រទេសកំពុងអភិវឌ្ឍ កើនឡើងដល់ ៩០%។

**MDG ទី៣**
លើកកម្ពស់សមភាពយេនឌ័រ និងផ្ដល់ភាពអង់អាចដល់ស្ត្រី

**វឌ្ឍនភាព៖** សមភាពយេនឌ័រ រវាងក្មេងប្រុស និងក្មេងស្រី មាននៅកម្រិតអប់រំបឋមសិក្សា ទូទាំងសកលលោក។

**MDG ទី៤**
កាត់បន្ថយមរណភាពកុមារ

**វឌ្ឍនភាព៖** ចាប់ពីឆ្នាំ១៩៩០ មក មានកុមារស្លាប់តិចជាងមុនចំនួន ១៧.០០០ នាក់ ជារៀងរាល់ថ្ងៃ។

**MDG ទី៥**
លើកកម្ពស់សុខភាពមាតា

**វឌ្ឍនភាព៖** អត្រាមរណភាពមាតាថយចុះ ៤៥% ចន្លោះពីឆ្នាំ១៩៩០ ដល់ ២០១៣។

**MDG ទី៦**
ប្រយុទ្ធប្រឆាំងនឹងមេរោគ/ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺផ្សេងទៀត

**វឌ្ឍនភាព៖** មានករណីស្លាប់ដោយសារជំងឺគ្រុនចាញ់តិចជាងមុនចំនួន ៣,៣ លាន ករណី ចន្លោះពីឆ្នាំ២០០០ ដល់ ២០១០។

**MDG ទី៧**
ធានានិរន្តរភាពបរិស្ថាន

**វឌ្ឍនភាព៖** មនុស្ស ២,៣ ពាន់លាននាក់ មានទឹកស្អាតបរិភោគ ចន្លោះពីឆ្នាំ១៩៩០ ដល់២០១២។

**MDG ទី៨**
បង្កើតភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍ

**វឌ្ឍនភាព៖** ជំនួយអភិវឌ្ឍន៍ផ្លូវការ កើនឡើងដល់កម្រិតខ្ពស់ដែលមិនធ្លាប់មានរហូតដល់ ១៣៤ ពាន់លានដុល្លារ ក្នុងឆ្នាំ២០១៣។

## គោលដៅសកលទាំង១៧

សូមគូសរង្វង់ជុំវិញគោលដៅសកល ដែលអ្នកគិតថាជាអាទិភាពថ្មីសម្រាប់ពិភពលោក។



Data source: http://www.un.org/millenniumgoals/poverty.shtml

ALDEAS INFANTILES SOS INTERNACIONAL

ChildFund International

CHI Child Helpline International

DEFENSA DE NIÑAS Y NIÑOS INTERNACIONAL DN
DEFENSE DES ENFANTS INTERNATIONAL DE
DEFENCE FOR CHILDREN INTERNATIONAL DC

ecpat

CONO SUR FMSI
Para el bien de los niños
Fundación Marista para la Solidaridad Internacional Onlus

International Centre FOR MISSING & EXPLOITED CHILDREN

iin Instituto Interamericano del Niño, la Niña y Adolescentes
Organismo Especializado de la OEA

red ANDI américa latina

REDLAMYC

Save the Children

Plan

unicef

viva juntos por la niñez

WORLD ALLIANCE OF YMCAs

World Vision
Visión Mundial

WORLD'S LARGEST LESSON

Royal Geographical Society with IBG
Advancing geography and geographical learning

Movimiento Mundial por la Infancia de Latinoamérica y El Caribe

**The Latin America and Caribbean movement for Children (MMI-LAC)** គឺជាសម្ព័ន្ធជាយុទ្ធសាស្ត្រអង្គការនិងបណ្ដាញនាំមុខគេក្នុងតំបន់នេះ ដែលធ្វើការងារដើម្បីលើកកម្ពស់ និងការពារសិទ្ធិរបស់កុមារនិងក្មេងជំទង់។ អង្គការជាសមាជិករបស់សម្ព័ន្ធនេះរួមមាន អង្គការ YMCA, SOS, Child Fund, Child Helpline, Defense for Children International – DCI, ECPAT, Inter-America Children's Institute (IIN) of OAS, Plan International, The Latin America and Caribbean Network for the defense of the Rights of Child and Adolescent (REDLAMYC), ANDI International, Save the Children, UNICEF និង World Vision International រួមទាំង International Centre for Missing and Exploited Children (ICMEC), the Foundation Marist Solidarity International (FMSI) និង Viva Network ជាអ្នកសង្កេតការណ៍។

MMI-LAC ពង្រឹងការលើកកម្ពស់ និងការការពារសិទ្ធិកុមារ និងក្មេងជំទង់ នៅអាមេរិកឡាទីន និងការីបៀន តាមរយៈ ក) កៀងគរធនធាននានា ដើម្បីលើកកម្ពស់សិទ្ធិរបស់កុមារ និងក្មេងជំទង់ ខ) រៀបចំកិច្ចពិភាក្សាពិគ្រោះយោបល់ ខ) រៀបចំកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនប្រសិទ្ធភាពនៃការតស៊ូមតិសិទ្ធិកុមារ គ) ជម្រុញឲ្យមានការផ្លាស់ប្ដូរបទពិសោធជោគជ័យនានា និងចងក្រងបទពិសោធទាំងនោះជាប្រព័ន្ធ និង ឃ) ផ្ដល់ការគាំទ្រដល់ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពរវាងសង្គមស៊ីវិល កុមារ និងក្មេងជំទង់ រដ្ឋ អង្គការអន្តរជាតិ និងទីភ្នាក់ងារពហុភាគី។